ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃ កិច្ចប្រជុំលើកទី២ គណៈកម្មាធិការចម្រុះ
# ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច រវាងកម្ពុជា និងបេឡារុស

ថ្ងៃទី២៩-៣០ ខែមិថុនា ឆ្នាំ២០១៧ រដ្ឋធានីមីនស្ក សាធារណៈរដ្ឋបេឡារុស

*****

កាលពីថ្ងៃទី២៩-៣០ ខែមិថុនា ឆ្នាំ២០១៧ នៅទីក្រុងមីនស្ក សាធារណរដ្ឋបេឡារុស **លោកជំទាវ ពីករ៉េត កំរង** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មតំណាង ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំលើកទី២ គណៈកម្មាធិការចម្រុះស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបេឡារុស ជាមួយ ឯកឧត្តម **ជេនណាឌី ស្វេឌ័រស្គី** (Gennady Svidersky) អនុរដ្ឋមន្ត្រីទី១ ក្រសួងឧស្សាហកម្មនៃសាធារណរដ្ឋបេឡារុស។ កិច្ចប្រជុំនេះក៏មានការចូលរួមពីតំណាងអន្តរក្រសួង និងមន្ត្រីនៃភាគីទាំងពីរផងដែរ។

កិច្ចប្រជុំនេះមានគោលបំណង ១)បន្តតាមដានវឌ្ឍនភាពការងារកិច្ចសហប្រតិបត្តិការ និងពិនិត្យការអនុវត្តតាមកិច្ចព្រមព្រៀងដែលភាគីទាំងពីរបានចុះហត្ថលេខានាអំឡុងដំណើរទស្សនកិច្ចការងាររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់សាធារណរដ្ឋបេឡារុសកាលពីឆ្នាំ២០១៤កន្លងទៅ និង ២)បន្តពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច និងបណ្តាវិស័យអាទិភាពផ្សេងៗទៀតឱ្យកាន់តែមានភាពស៊ីជម្រៅ និងទូលំទូលាយ។

ភាគីទាំងពីរបានលើកអំពីសារៈសំខាន់នៃកិច្ចព្រមព្រៀងដែលសម្រេចបានកន្លងមក ជាពិសេសកិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចកម្ពុជា-បេឡារុសដែលជាមូលដ្ឋានមួយដ៏សំខាន់ក្នុងការគាំទ្រ និងសម្រួលដល់ប្រតិបត្តិការពាណិជ្ជកម្ម ទំនាក់ទំនងវិស័យឯកជន និងធុរកិច្ច ដើម្បីឈានទៅសម្រេចគោលដៅទំហំពាណិជ្ជកម្មទ្វេភាគី ២០០លានដុល្លារអាមេរិកនៅឆ្នាំ២០២០។ ក្នុងនោះដែរ ភាគីទាំងពីរបានគូសបញ្ជាក់អំពីភាពបំពេញគ្នាទៅវិញទៅមកលើវិស័យកសិកម្ម និងឧស្សាហកម្ម ដោយយល់ឃើញថាប្រទេសទាំងពីរជាប្រទេសកសិកម្មផលិត និងនាំចូលកសិផល ឧបករណ៍ និងគ្រឿងចក្រកសិកម្មផ្សេងៗ។ ស្របគ្នានេះដែរ កម្ពុជាបានលើកទឹកចិត្តឱ្យភាគីបេឡារុសជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារបេឡារុស និងពិនិត្យលទ្ធភាពបង្កើតរោងចក្រតំឡើងរថយន្តក្រុង និងផលិតសំបកកង់យានយន្តដើម្បីផ្គត់ផ្គង់នៅទីផ្សារកម្ពុជា និងក្នុងតំបន់ ហើយក៏បានជម្រាបអំពីសក្តានុពលផលិតផលកសិកម្ម ពិសេសជ័រកៅស៊ូធម្មជាតិរបស់កម្ពុជាផងដែរ។

ដោយបេឡារុសជាប្រទេសមានភាពរីកចម្រើនខ្លាំងក្នុងវិស័យព័ត៌មានវិទ្យា និងវិទ្យាសាស្ត្រ ភាគីបេឡារុសបានសន្យាគាំទ្រដល់ការអភិវឌ្ឍ និងផ្ទេរចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសទំនើបដល់ភាគីកម្ពុជាតាមរយៈការផ្លាស់ប្តូរកម្មវិធីសិក្សា និងកិច្ចសហប្រតិបត្តិការដោយផ្ទាល់លើវិស័យអប់រំ និងការបណ្តុះបណ្តាលធនធានមនុស្ស។ ក្រៅពីវិស័យសំខាន់ៗខាងលើ អង្គប្រជុំក៏បានផ្តោតការយកចិត្តទុកដាក់លើការពង្រឹង និងពង្រីកវិស័យផ្សេងទៀតដូចជា៖ ហិរញ្ញវត្ថុ និងធនាគារ ថាមពល ស្តង់ដារ និងមាត្រសាស្ត្រ ទេសចរណ៍ និងវប្បធម៌ផងដែរ។

លោកជំទាវ និងឯកឧត្តមសហប្រធានកិច្ចប្រជុំ បានគូសបញ្ជាក់ថា ភាពជាដៃគូជិតស្និតរវាងកម្ពុជា និងបេឡារុសនឹងត្រូវបានពង្រឹងថែមមួយកំរិតទៀត តាមរយៈកិច្ចសហប្រតិបត្តិការល្អ និងការខិតខំប្រឹងប្រែងពីសំណាក់ថ្នាក់ដឹកនាំមន្ត្រីពាក់ព័ន្ធ និងប្រជាជាតិនៃប្រទេសទាំងពីរ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ ភាគីទាំងពីរបានចុះហត្ថលេខាលើកំណត់ហេតុរួមនៃកិច្ចប្រជុំនេះ នៅក្នុងបរិយាកាសដ៏ស្និតស្នាល និងសប្បាយរីករាយ និងបានព្រមព្រៀងថាការរៀបចំកិច្ចប្រជុំលើកទី៣ គណៈកម្មាធិការចម្រុះស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងកម្ពុជា និងបេឡារុស នឹងប្រារព្ធធ្វើនៅព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១៩។

*ភ្នំពេញ ថ្ងៃច័ន្ទ ទី០៣ ខែកក្កដា ឆ្នាំ២០១៧*

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម